**ឯកសារសម្រាប់ស្នើសុំទិដ្ឋាការក្រោមវិធានការថ្មី(២៩)ស្តីពីការរឹតបណ្តឹងព្រំដែន**

**ទិដ្ឋាការរយៈពេលខ្លី (គោលបំណងពាណិជ្ជកម្ម)**

ឯកសារសម្រាប់ស្នើសុំទិដ្ឋាការស្នាក់នៅរយៈពេលខ្លីក្នុងគោលបំណងទៅបំពេញការងារ(សន្និសីទ កិច្ចពិភាក្សាពាណិជ្ជកម្ម កម្មវិធីផ្លាស់ប្តូរវប្បធម៌ កម្មវិធីផ្លាស់ប្តូរកីឡា។ល។) ក្រោមវិធានការថ្មី(២៩)មានដូចខាងក្រោម។ យើងនឹងមិនទទួលពាក្យស្នើរសុំរបស់អ្នកក្នុងករណីឯកសារមិនមានគ្រប់លក្ខខណ្ឌ។

ចំពោះទិដ្ឋាការស្នាក់នៅរយៈពេលខ្លីក្នុងគោលបំណងទៅលេងមិត្តភក្តិ ឬទៅទេសចរណ៍មិនអាចស្នើរសុំបានទេ។

| ឯកសារតម្រូវ | ចំនួន | ចំណាំ |
|---|---|---|
| *រៀបចំដោយបេក្ខជន(នៅស្រុកខ្មែរ)* | | |
| លិខិតឆ្លងដែន | ១ | • ត្រូវមានទំព័រសម្រាប់បិទទិដ្ឋាការ២ឬច្រើនជាង២ទំព័រ |
| ថតចម្លងលិខិតឆ្លងដែន | ១ | • ថតចម្លងតែទំព័រដែលមានព័ត៌មានផ្ទាល់ខ្លួន |
| ពាក្យស្នើសុំទិដ្ឋាការ | ១ | • សូមបិតរូបថត១សន្លឹក( 4.5x3.5cm ផ្ទៃពណ៌ស)<br>*យើងនឹងមិនទទួលពាក្យស្នើរសុំរបស់អ្នកករណីអ្នកមិនបំពេញគ្រប់លក្ខខណ្ឌ |
| លិខិតបេសកកម្ម<br>(ចេញដោយក្រុមហ៊ុនឬស្ថាប័ននៅខ្មែរ) | ១ | • មិនមានការកំណត់ទម្រង់<br>• មានសរសេរឈ្មោះបេក្ខជន,មុខតំណែង,គោលបំណង,រយៈពេល និង ការរ៉ាប់រងលើការចំណាយ |
| *រៀបចំដោយអ្នកអញ្ជើញ(នៅប្រទេសជប៉ុន)* | | |
| លិខិតអញ្ជើញ | ១ | |
| កិច្ចសន្យា | ១ | *ភ្ជាប់១សន្លឹកមកជាមួយលិខិតអញ្ជើញ |
| លិខិតធានា | ១ | |
| តារាងឈ្មោះបេក្ខជន | ១ | • ករណីបេក្ខជនមានច្រើន (ចាប់ពី២នាក់ឡើង) |
| តារាងកម្មវិធីស្នាក់នៅជប៉ុន | ១ | • ពិពណ៌នាអំពីសកម្មភាពប្រចាំថ្ងៃចាប់ពីថ្ងៃចូលរហូតដល់ថ្ងៃចេញពីប្រទេសជប៉ុន, ព័ត៌មានហោះហើរចូលនិងចេញ, ឈ្មោះទីកន្លែងចូល និងលេខឬអាស័យដ្ឋានទំនាក់ទំនង |
| ឯកសារស្តីពីស្ថាប័នឬក្រុមហ៊ុនអញ្ជើញ | ១ | • វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុន/ស្ថាបន ឬប្រវត្តិសង្ខេបក្រុមហ៊ុន/ស្ថាបន<br>• ខិតប័ណ្ណប្រវត្តិរូបក្រុមហ៊ុន (ពិពណ៌នាអំពីការពិតសកម្មភាព និងខ្លឹមសាររបស់ក្រុមហ៊ុន) |
| វិញ្ញាបណ្ណប័ត្រសុំតាមកម្មវិធីក្នុងប្រព័ន្ធ Entrants, Returnees Follow-up System (ERFS) | ១ | • បំពេញតាមអ៊ីនធឺណែត<br>លម្អិតសូមយោងតាមគេហទំព័រនេះ Ministry of Health, Labour, and Welfare (ជាភាសាជប៉ុនតែប៉ុណ្ណោះ) |

- អ្នកអាចនឹងត្រូវបានទាក់ទងអោយមកដាក់ឯកសារបន្ថែមទៀតនៅពេលពិនិត្យឃើញមានព័ត៌មានមិនច្បាស់នៅត្រង់កន្លែងណាមួយ។
- សូមរៀបចំឯកសារព្រីនម្ខាងលើក្រដាសA4 ។
- តម្រូវអោយដាក់ឯកសារធ្វើថ្មីៗក្នុងកំឡុងពេល៣បី។
- សូមដាក់ឯកសារច្បាប់ដើម។